# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១០០៧ ព្រ.៣.២៦-៩៧

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការខេត្តកំពង់ឆ្នាំង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការអនុវត្តន៍ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ២១ក្រ ចុះថ្ងៃទី០៨-០៣-១៩៩៣ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងក្រោយពីបានពិនិត្យលើរបាយការណ៍ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងសំណុំលិខិតក្នុងបណ្តឹងរបស់ឈ្មោះប្រុក កែប មកក្រសួងបានកត់សម្គាល់ឃើញថាលោកចៅក្រម ឡេ ស៊ីថុន ដែលបានកាត់សេចក្តីក្នុងករណីឈ្មោះប្រុក កែប មានទំនាស់រឿងដីធ្លីជាមួយឈ្មោះព្រីង សំអាត, លោក ឡេ ស៊ីថុន ជំនុំជម្រះសំណុំរឿងខាងលើដោយពុំមានតំណាងអយ្យការចូលរួម គឺជាការអនុវត្តន៍ផ្ទុយនឹងមាត្រា៥១ និង៩៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

មួយផ្នែកទៀតចំពោះការបដិសេធមិនសួរយកចម្លើយពីសាក្សីរបស់ឈ្មោះប្រុក កែប នៅពេលសវនាការឲ្យលោកចៅក្រមជំនុំជម្រះសំអាងហេតុថាសាក្សីនេះឆ្លើយខុសពីការពិត ក្នុងពេលស៊ើបអង្កេតរបស់មន្ត្រីយុត្តិធម៌ស្រុកកំពង់លែងនោះក៏ជាកំហុសរបស់លោកចៅក្រមជំនុំជម្រះដែលអនុវត្តផ្ទុយនឹងមាត្រា១២៥,១៣៣,១៣៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ២១ក្រ ចុះថ្ងៃទី០៨-០៣-១៩៩៣ ដែរ ។

អាស្រ័យហេតុនេះ សូមលោកប្រធានធ្វើការណែនាំដល់លោកចៅក្រមក្នុងតុលាការ សាមីឱ្យយកចិត្តទុកដាក់ឱ្យបានខ្ពស់ក្នុងការជំនុំជម្រះរឿងក្តីនីមួយៗ ធ្វើយ៉េងណាអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-ព្រះរាជអាជ្ញាអមតុលាការខេត្ត.ក្រុង
-ប្រធានតុលាការខេត្តក្រុង
-ដើម្បីជ្រាបនិងអនុវត្ត